# គោលការណ៍ណែនាំអំពីការដាក់ពាក្យស្នើសុំទិដ្ឋាការទេសចរណ៍តាមរយៈក្រុមហ៊ុនទេសចរណ៍តំណាងដែលត្រូវបានទទួលស្គាល់

ស្ថានទូតជប៉ុនប្រចាំប្រទេសកម្ពុជា
កែតម្រូវថ្ងៃទី១០ ខែតុលា ឆ្នាំ២០២២

## 1. លក្ខខណ្ឌក្នុងការស្នើសុំចុះបញ្ជីក្រុមហ៊ុនទេសចរណ៍តំណាង

1.1. ដើម្បីក្លាយជាក្រុមហ៊ុនទេសចរណ៍តំណាងដែលមានការទទួលស្គាល់ ក្រុមហ៊ុនទាំងអស់ត្រូវបំពេញទៅតាមលក្ខខណ្ឌដូចខាងក្រោម៖

ក. ទទួលបានការអនុញ្ញាតអោយធ្វើប្រតិបត្តិការសេវាកម្មទេសចរណ៍នៅកម្ពុជា។

ខ. បានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម រួមទាំងបានបង់ពន្ធសហគ្រាសត្រឹមត្រូវ និងមានកំណត់ត្រាសកម្មភាពអាជីវកម្មរយៈពេល៣ឆ្នាំកន្លងមក បន្ទាប់ពីបានចុះបញ្ជី។

គ. មានដាក់បង្ហាញតារាងតម្លៃទិដ្ឋាការអោយបានច្បាស់លាស់នៅក្នុងក្រុមហ៊ុន។

ឃ. ក្រុមហ៊ុនតំណាងគួរមានបញ្ចូលធានារ៉ាប់រងដំណើរកម្សាន្តក្រៅប្រទេស។

1.2. ចំពោះក្រុមហ៊ុនទេសចរណ៍ជប៉ុន (ក្រុមហ៊ុន បុត្រសម្ព័ន្ធក្នុងស្រុក) សាខា ឬការិយាល័យតំណាងដែលបានចុះបញ្ជីពាណិជ្ជកម្មប្រភេទទី១នៅប្រទេសជប៉ុន លក្ខខណ្ឌក្នុងចំណុច (ខ) ត្រូវបានលើកលែង។

## 2. សុពលភាពនៃការចុះបញ្ជីក្នុងនាមជាក្រុមហ៊ុនទេសចរណ៍តំណាង

សុពលភាពក្នុងនាមជាក្រុមហ៊ុនតំណាងដែលបានចុះបញ្ជីរួចគឺគិតត្រឹមថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំនីមួយៗ ដោយមិនគិតពីថ្ងៃដែលបានចុះបញ្ជី។

## 3. បុគ្គលិកក្រុមហ៊ុនទេសចរណ៍ដែលអាចឈរឈ្មោះជាអ្នកតំណាង

ក. បុគ្គលដែលមានសញ្ជាតិខ្មែរ

ខ. ជនបរទេសដែលមានសិទ្ធស្នាក់នៅប្រទេសកម្ពុជារយៈពេលវែង

## 4. សាមីជនដែលអាចស្នើសុំទិដ្ឋាការតាមរយៈក្រុមហ៊ុនទេសចរណ៍

សាមីជនដែលមានសញ្ជាតិខ្មែរ និង ជនបរទេសដែលមានសិទ្ធស្នាក់នៅប្រទេសកម្ពុជារយៈពេលវែងអាចស្នើសុំទិដ្ឋាការប្រទេសជប៉ុនរយៈពេលខ្លីបាន។

**5. ប្រភេទទិដ្ឋាការដែលអាចស្នើតាមរយៈក្រុមហ៊ុនទេសចរណ៍តំណាងបាន**

ក. ទិដ្ឋាការទេសចរណ៍ (ចេញចូល១ដង) រយៈពេលស្នាក់នៅជប៉ុន ក្រោម១៥ថ្ងៃ។

ខ. សម្រាប់បុគ្គលិកដែលធ្វើដំណើរអមជាមួយក្រុមហ៊ុនទេសចរ អាចស្នើសុំទិដ្ឋាការចេញចូលច្រើនដងបាន (រយៈពេលស្នាក់នៅ១៥ថ្ងៃ សុពលភាព១ឆ្នាំ)។ ឯកសារតម្រូវរួមមាន៖

- គម្រោងកម្មវិធីធ្វើដំណើររយៈពេល១ឆ្នាំ
- លិខិតធានាដែលចេញដោយក្រុមហ៊ុន (បញ្ជាក់ពីការធានាលើថ្លៃចំណាយ និងការគោរពច្បាប់ប្រទេសជប៉ុន)
- លិខិតបញ្ជាក់ការងារ

**6. ឯកសារ និងនីតិវិធីក្នុងការស្នើសុំទិដ្ឋាការតាមរយៈក្រុមហ៊ុនទេសចរណ៍តំណាង**

ក្រុមហ៊ុនទេសចរណ៍តំណាងត្រូវដាក់ឯកសារដូចខាងក្រោម៖

ក. លិខិតស្នើសុំក្នុងនាមជាអ្នកតំណាងដាក់ពាក្យស្នើសុំ (ស្របតាមទម្រង់របស់ស្ថានទូត)

ខ. បង្កាន់ដៃទទួលពាក្យ (ស្របតាមទម្រង់របស់ស្ថានទូត)

គ. បញ្ជីរាយនាមសាមីជនស្នើសុំទិដ្ឋាការ (ឈ្មោះ, ថ្ងៃខែឆ្នាំកំណើត, លេខលិខិតឆ្លងដែន)

ឃ. លិខិតឆ្លងដែនសាមីជនស្នើសុំទិដ្ឋាការ (សូមដោះគម្រប និងដកឯកសារដែលមានកៀបនៅក្នុងលិខិតឆ្លងដែនចេញនៅពេលយកមកដាក់។ សូមរៀបចំឯកសារ និងលិខិតឆ្លងដែនទាំងនោះអោយស្របតាមលេខរៀងដែលមាននៅក្នុងបញ្ជីរាយនាមសាមីជនស្នើសុំទិដ្ឋាការ)

ង. ពាក្យស្នើសុំទិដ្ឋាការ (ចុះហត្ថលេខាដោយសាមីខ្លួន)

ច. ឯកសារស្របតាមការណែនាំដែលមាននៅក្នុងគេហទំព័រស្ថានទូតជប៉ុន (ប្រភេទទេសចរណ៍, សូមចូលទៅកាន់គេហទំព័រស្ថានទូតដើម្បីមើលឯកសារតម្រូវការ)

**7. កំណត់សម្គាល់ពិសេសសម្រាប់ក្រុមហ៊ុនទេសចរណ៍តំណាង**

ក. ជាគោលការណ៍ ស្ថានទូតមិនអនុញ្ញាតឲ្យស្នើសុំដកពាក្យស្នើសុំ (ឬខ្ចីលិខិតឆ្លងដែនយកទៅប្រើប្រាស់បណ្តោះអាសន្ន) ក្នុងអំឡុងពេលពិនិត្យសម្រេចលើទិដ្ឋាការឡើយ។ ដោយឡែក បើរយៈពេលពិនិត្យសម្រេចទិដ្ឋាការលើសពី៥ថ្ងៃ សាមីខ្លួនអាចធ្វើលិខិតដើម្បីស្នើដកពាក្យស្នើសុំ (ឬខ្ចីលិខិតឆ្លងដែនយកទៅប្រើប្រាស់បណ្តោះអាសន្ន)បាន។

ខ. ចំពោះការស្នើសុំលុបចោលទិដ្ឋាការដែលបានផ្តល់ជូនរួច តម្រូវអោយសាមីខ្លួនធ្វើលិខិតស្នើសុំលុបចោលដោយខ្លួនឯងផ្ទាល់។

គ. ក្នុងករណីមានការផ្អាកដំណើរកម្សាន្តដោយមូលហេតុប្រធានសក្តិ ក្រុមហ៊ុនតំណាងអាចដាក់លិខិតស្នើសុំដកពាក្យស្នើសុំ ឬលុបចោលទិដ្ឋាការដោយភ្ជាប់មកជាមួយឯកសារពាក់ព័ន្ធ។

## 8. ការរាយការណ៍មកស្ថានទូតប្រចាំប្រទេសកម្ពុជា

ករណីសាមីជនស្នើសុំទិដ្ឋាការបានប្រព្រឹត្តិអំពើខុសច្បាប់នៅប្រទេសជប៉ុន (រួមបញ្ចូលទាំងការស្នាក់នៅខុសច្បាប់) ក្រុមហ៊ុនតំណាងត្រូវរាយការណ៍មកស្ថានទូតអោយបានលឿនតាមដែលអាចធ្វើទៅបាន។

## 9. ឯកសារសម្រាប់ដាក់ពាក្យស្នើសុំចុះបញ្ជី និងបន្តសុពលភាពក្នុងនាមជាក្រុមហ៊ុនទេសចរណ៍តំណាង

**9.1.** ក្រុមហ៊ុនដែលមានបំណងចង់ស្នើសុំចុះបញ្ជី ឬបន្តសុពលភាពក្នុងនាមជាក្រុមហ៊ុនទេសចរណ៍តំណាងត្រូវដាក់ឯកសារដូចខាងក្រោម៖

ក. ពាក្យស្នើសុំក្នុងនាមជាអ្នកតំណាងដាក់ពាក្យស្នើសុំ/ទទួលទិដ្ឋាការ ១ច្បាប់

ខ. អាជ្ញាបណ្ណទេសចរណ៍ ១ច្បាប់

គ. ប័ណ្ណពន្ធប៉ាតង់ ១ច្បាប់

ឃ. វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម (សម្រាប់ក្រុមហ៊ុនស្នើសុំចុះឈ្មោះថ្មី តែប៉ុណ្ណោះ) ១ច្បាប់

ង. ឯកសារប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ (សម្រាប់ក្រុមហ៊ុនស្នើសុំចុះឈ្មោះថ្មី តែប៉ុណ្ណោះ) ១ច្បាប់

ច. បញ្ជីរាយនាមសាមីជនដែលបានដាក់ស្នើទិដ្ឋាការកាលពីឆ្នាំមុន (សម្រាប់ក្រុមហ៊ុនស្នើសុំបន្ត តែប៉ុណ្ណោះ)

**9.2.** ក្រុមហ៊ុនទេសចរណ៍តំណាងអាចធ្វើការស្នើសុំបន្តសុពលភាព ចាប់ពីថ្ងៃទី១ ខែតុលា រហូតដល់ថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំនីមួយៗ។

**9.3.** ការស្នើសុំបន្តសុពលភាពនឹងមិនត្រូវបានអនុញ្ញាត ប្រសិនបើក្រុមហ៊ុនតំណាងនៅស្ថិតក្នុងកំឡុងពេលព្យួរសិទ្ធធ្វើជាអ្នកតំណាង។

## 10. ការផ្លាស់ប្តូរបុគ្គលិកតំណាងនៃក្រុមហ៊ុនទេសចរណ៍

ក. ក្នុងករណីបុគ្គលិកតំណាងលាឈប់ ក្រុមហ៊ុនត្រូវផ្តល់ដំណឹងមកកាន់ស្ថានទូតឲ្យបានរហ័ស។

ខ. ក្នុងករណីមានការផ្លាស់ប្តូរបុគ្គលិកតំណាង ក្រុមហ៊ុនត្រូវដាក់ពាក្យស្នើសុំអ្នកតំណាងដាក់ពាក្យ/ទទួលទិដ្ឋាការសារជាថ្មី។

គ. ក្រុមហ៊ុនតំណាងត្រូវផ្តល់ដំណឹងមកកាន់ស្ថានទូត និងត្រូវយកលិខិតឆ្លងដែនដែលមានបិទទិដ្ឋាការចេញចូលប្រទេសជប៉ុនច្រើនដង(Multiple entries Visa) របស់បុគ្គលិកដែលលាឈប់នោះមកស្ថានទូតដើម្បីធ្វើមោឃភាពទិដ្ឋាការ។

## 11. ការព្រមាន

**11.1.** លិខិតព្រមាននឹងត្រូវបានផ្តល់ជូនក្នុងករណីសកម្មភាពដូចខាងក្រោមត្រូវបានកត់សម្គាល់៖

ក. បំពេញ និងរៀបចំឯកសារនៅបរិវេណបន្ទប់រង់ចាំកុងស៊ុល
ខ. ធ្វើឲ្យកខ្វក់លើឯកសារសម្រាប់ស្នើសុំទិដ្ឋាការ
គ. រំលោភបំពានលើគោលការណ៍ណែនាំ
ឃ. មកដាក់ពាក្យស្នើសុំទិដ្ឋាការដោយបុគ្គលិកតំណាងដែលមិនបានចុះឈ្មោះក្នុងបញ្ជី
ង. មិនប្រតិបត្តិតាមការណែនាំរបស់ស្ថានទូត ស្តីអំពីការស្នើសុំទិដ្ឋាការដោយអ្នកតំណាង

**11.2.** ករណីទទួលបានការព្រមានគ្រប់ចំនួនកំណត់ណាមួយ ក្នុងអំឡុងពេលចុះឈ្មោះជាក្រុមហ៊ុនតំណាង វិធានការនៅប្រការទី១២ នឹងត្រូវបានអនុវត្ត។

**11.3.** លិខិតប្រមាននឹងត្រូវបានផ្តល់ជូនក្រុមហ៊ុនតំណាងជាលាយលក្ខអក្សរ។

**11.4.** ចំនួននៃការព្រមាននឹងត្រូវបានកំណត់សារជាថ្មី ប្រសិនបើការស្នើសុំបន្តជាក្រុមហ៊ុនតំណាងត្រូវបានអនុញ្ញាត។

**11.5.** ករណីក្រុមហ៊ុនទេសចរណ៍ត្រូវបានពិន័យយោងតាមប្រការទី១២ ហើយត្រូវបានអនុញ្ញាតអោយចុះបញ្ជីជាក្រុមហ៊ុនតំណាងសារជាថ្មីវិញ នោះចំនួននៃការព្រមាននឹងត្រូវបានកំណត់សារជាថ្មី។

**11.6.** ការព្រមានផ្ទាល់មាត់នឹងត្រូវបានធ្វើឡើងចំពោះអ្នកតំណាងដែលមិនគោរព ឬប្រព្រឹត្តិកំហុសច្រំដែលក្នុងការបំពេញ និងរៀបចំឯកសារ។ ដោយឡែកលិខិតប្រមាននឹងត្រូវផ្តល់ជូន ក្នុងករណីដែលគ្មានការកែប្រែ បន្ទាប់ពីទទួលបានការព្រមានផ្ទាល់មាត់ជាច្រើនដង។

## 12. ការពិន័យ

ករណីក្រុមហ៊ុន និងបុគ្គលិកតំណាងមានការក្លែងបន្លំឯកសារ វិធានការខាងក្រោមនឹងត្រូវបានអនុវត្តះ

**12.1.** ផ្អាកសិទ្ធជាក្រុមហ៊ុនទេសចរណ៍តំណាង (រយៈពេល៣ខែ)
ក. ករណីទទួលបានលិខិតប្រមាន២ដង
ខ.ការព្រមាន១ដង នឹងត្រូវរាប់ស្មើ២ដង ប្រសិនបើក្រុមហ៊ុនបានប្រព្រឹត្តទង្វើធ្វេសប្រហែសធ្ងន់ធ្ងរក្នុងអំឡុងពេលជាក្រុមហ៊ុនតំណាង។

**12.2.** ផ្អាកសិទ្ធជាក្រុមហ៊ុនទេសចរណ៍តំណាង (រយៈពេល៦ខែ)
ក. នៅពេលរកឃើញថាបុគ្គលិកតំណាងបានបន្លំការដាក់ពាក្យស្នើសុំ (បុគ្គលិកតំណាងរបស់ក្រុមហ៊ុនបានដាក់ពាក្យស្នើសុំក្នុងអំឡុងពេលឈប់សម្រាកការងារ ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន)។
ខ. រក្សាទុកឯកសារស្នើសុំមិនបានល្អ ដូចជាធ្វើឲ្យមានការខូចខាតឬ បាត់បង់ជាដើម។
គ. នៅពេលសម្គាល់ឃើញថា មានការខ្វះខាតក្នុងការគ្រប់គ្រងព័ត៌មានឯកជន ទោះបីជាមិនទាន់ឈានដល់ការធ្លាយព័ត៌មានក៏ដោយ។

**12.3.** ផ្អាកសិទ្ធជាក្រុមហ៊ុនទេសចរណ៍តំណាង (រយៈពេល១ឆ្នាំ)
ក. ក្នុងករណីធ្វើអោយបាត់លិខិតឆ្លងដែន

ខ. ក្នុងករណីព័ត៌មានឯកជនត្រូវបានធ្លាយដោយសារការធ្វេសប្រហែស

គ. ក្នុងករណីសាមីជនដែលទទួលបានទិដ្ឋាការតាមរយៈបុគ្គលិកតំណាងបានស្នាក់នៅប្រទេសជប៉ុនដោយខុសច្បាប់។

ឃ. ក្នុងករណីសាមីជនដែលបានទិដ្ឋាការទទួលស្គាល់ថា ខ្លួនបានប្រព្រឹត្តិអំពើខុសច្បាប់ (រួមបញ្ចូលទាំងការស្នាក់នៅខុសច្បាប់) ប៉ុន្តែមិនបានរាយការណ៍មកកាន់ស្ថានទូត។

ង. ក្នុងករណីស្ថានទូតជប៉ុននៅកម្ពុជាសម្រេចថា មានការចាំបាច់ត្រូវផ្អាកសិទ្ធរបស់ក្រុមហ៊ុនតំណាង។

**12.4.** លុបចោលសិទ្ធជាក្រុមហ៊ុនតំណាង

ក. ករណីក្រុមហ៊ុនតំណាងក្លែងបន្លំព័ត៌មានឬ ឯកសារស្នើសុំ

ខ. ករណីក្រុមហ៊ុនតំណាងទម្លាយព័ត៌មានឯកជនដោយចេតនា

គ. ករណីក្រុមហ៊ុនតំណាងជួយសាមីជនដាក់ពាក្យ ក្នុងការស្នាក់នៅប្រទេសជប៉ុនដោយខុសច្បាប់

ឃ. ករណីក្រុមហ៊ុនតំណាងទទួលប្រាក់ដោយមិនប្រក្រតី ដូចជាការយកប្រាក់បន្ថែមពីសាមីជនស្នើសុំដោយគ្មានការពន្យល់ច្បាស់លាស់ទុកជាមុន

ង. ករណីដែលស្ថានទូតជប៉ុននៅកម្ពុជាសម្រេចថា មានការចាំបាច់ត្រូវផ្អាកសិទ្ធរបស់ក្រុមហ៊ុនតំណាងដោយក្រុមហ៊ុនបានប្រព្រឹត្តិអំពើខុសច្បាប់។

ច. ករណីដែលស្ថានទូតជប៉ុននៅកម្ពុជាសម្រេចថា មានការចាំបាច់ត្រូវផ្អាកសិទ្ធរបស់ក្រុមហ៊ុនតំណាងដោយមូលហេតុផ្សេងៗ ក្រៅពីករណីដែលបានលើកឡើងខាងលើ។

**12.5.** ក្រុមហ៊ុនតំណាងដែលត្រូវបានផ្អាកឬ លុបចោលសិទ្ធជាអ្នកតំណាង ក្នុងរយៈពេលលើសពី ៦ខែ ឯកសារស្នើសុំទិដ្ឋាការដែលបានដាក់ចូលនឹងត្រូវបានផ្អាកការពិនិត្យ ហើយត្រូវប្រគល់ជូនទៅក្រុមហ៊ុនតំណាងវិញ។

**12.6.** សេចក្តីសម្រេចចំពោះក្រុមហ៊ុនតំណាងដែលត្រូវបានផ្អាក ឬលុបចោលសិទ្ធជាអ្នកតំណាងនឹងត្រូវបង្ហោះនៅលើគេហទំព័ររបស់ស្ថានទូតជប៉ុននៅកម្ពុជា ក៏ដូចជានៅតាមបញ្ជរកុងស៊ុល ហើយនឹងត្រូវបានលុបឈ្មោះចេញពីបញ្ជីក្រុមហ៊ុនទេសចរណ៍តំណាងផងដែរ។

## 13. រយៈពេលនៃការអនុវត្តន៍ការស្នើសុំដោយក្រុមហ៊ុនតំណាង

**13.1.** ការអនុវត្តន៍ការដាក់ពាក្យស្នើសុំទិដ្ឋាការដោយក្រុមហ៊ុនតំណាងនឹងចូលជាធរមានចាប់ពីថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២០ រហូតមានការប្រកាសបញ្ឈប់ការអនុវត្តន៍ដែលសម្រេចដោយក្រសួងការបរទេស ឬស្ថានទូតជប៉ុនប្រចាំប្រទេសកម្ពុជា។

**13.2.** ពាក្យស្នើសុំទិដ្ឋាការដែលត្រូវបានទទួលដោយស្ថានទូតជប៉ុននៅកម្ពុជាត្រឹមថ្ងៃចេញសេចក្តីប្រកាសបញ្ឈប់នោះនឹងត្រូវពិនិត្យសម្រេចស្របតាមលក្ខខណ្ឌដែលបានចែងខាងលើ។

**14. ផ្សេងៗ**

សម្រាប់សាមីជនធ្វើដំណើរកម្សាន្តជាក្រុមដែលចង់ស្នាក់នៅប្រទេសជប៉ុនលើស១៥ថ្ងៃ អ្នកតំណាងក្រុមគ្រួសារនីមួយៗត្រូវមកបង្ហាញខ្លួននៅស្ថានទូត។ ចំពោះការស្នើសុំទិដ្ឋាការក្រៅពីប្រភេទទិដ្ឋាការដែលបានចែងក្នុងប្រការ៥(ក) ខាងលើ នីតិវិធីនៃការស្នើសុំត្រូវរក្សាទុកដដែរ។ ករណីអនីតិជនមានអាយុក្រោម៦ឆ្នាំដែលមានអាណាព្យាបាលស្របច្បាប់អមដំណើរជាមួយ មិនតម្រូវឲ្យមកបង្ហាញខ្លួនទេ។